**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តតាកែវ

សំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៤
ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២២
សាលក្រមរដ្ឋប្បវេណីលេខ ២១ (ឈ)
ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២២

# សាលក្រមរដ្ឋប្បវេណី
# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២២

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**-ដើមចោទ:** ឈ្មោះ [redacted] ផេង ភេទប្រុស កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៨៧១៦៣៤ អាសយដ្ឋាននៅ[redacted]។

**-មេធាវីតំណាងដោយអាណត្តិ:** លោក [redacted] អត្តលេខ ២៣៦១ មានអាសយដ្ឋានការិយាល័យមេធាវី [redacted] ស្ថិតនៅផ្ទះលេខ[redacted] និងលោក [redacted] អត្តលេខ ២៤៥៦T នៃក្រុមមេធាវី [redacted] មានការិយាល័យ[redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ផេង ។

**-សហចុងចម្លើយ:** ឈ្មោះ [redacted] នៅ ភេទប្រុស កើតឆ្នាំ១៩៧០ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១០១៣១៩១៧៧ មានអាសយដ្ឋាននៅ[redacted] និងប្រពន្ធឈ្មោះ [redacted] រី ភេទស្រី កើតឆ្នាំ១៩៧២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១០០៧៦០៩៦១ មានអាសយដ្ឋាន[redacted]។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ:**

**១.១** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] រី សងប្រាក់ដើម ចំនួន ៤៥,000 USD (បួនម៉ឺនប្រាំពាន់ដុល្លាររអាមេរិក) មកឱ្យដើមចោទឈ្មោះ [redacted] ផេង ។

**១.២** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] រី សងការប្រាក់ឱ្យដើមចោទចំនួន ៣% (បីភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃមិនអនុវត្តកាតព្វកិច្ច រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួនជូនដើមចោទ។

**១.៣** សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងសេវាកម្មច្បាប់ចំនួន ២០,000 $ (ពីរម៉ឺនដុល្លារអាមេរិក) ពីចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] ។

**១.៤** ស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ចំណុចទី១ ។

**១.៥** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] រី បង់ពន្ធប្រាក់ប្រដាប់ក្តី និងពន្ធលើកម្មវត្ថុនៃបណ្តឹង ។

Scanned with CamScanner

**២.ការសង្ខេបរឿងក្តី**

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] បានមកខ្ចីប្រាក់ពីដើមចោទសម្រាប់យកទៅធ្វើការរកស៊ីចំនួន USD ៤៥,000 (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យាចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ព្រមទាំងមានលិខិតប្រគល់ទទួលប្រាក់ផងដែរ និងមានទ្រព្យធានាត្រឹមត្រូវតាមច្បាប់ ហើយមានមេធាវីប្រថាប់ត្រាបានឃើញ ព្រមទាំងបានបញ្ជាក់ថាគូភាគីនៃកិច្ចសន្យាពិតជាបានផ្តិតមេដៃនៅចំពោះមុខមេធាវីពិតប្រាកដមែន ដោយពុំមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ។ នៅក្នុងការខ្ចីប្រាក់នេះចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] បានព្រមព្រៀងជាមួយដើមចោទឈ្មោះ [redacted] ផេង កំណត់យកការប្រាក់ចំនួន ៣% ក្នុងមួយខែ ដោយកំណត់រយៈពេលនៃការខ្ចីចំនួន ០៥ខែ គិតចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ដោយបង់ការប្រាក់ឱ្យបានទៀតទាត់ជារៀងរាល់ខែ ប៉ុន្តែរាល់ខែចុងចម្លើយមិនបានបំពេញកាតព្វកិច្ចដូចក្នុងកិច្ចសន្យានោះទេ ដោយចុងចម្លើយបានបង់ការប្រាក់យឺតយ៉ាវមកដើមចោទ និងមិនបានបង់ការប្រាក់នៅខែចុងក្រោយឱ្យទៅដើមចោទតាមការកំណត់នោះទេ ទោះបីជាដើមចោទជូនដំណឹងឱ្យបង់ការប្រាក់ឱ្យបានទៀតទាត់យ៉ាងណាក៏ដោយ ក៏ចុងចម្លើយនៅតែព្រងើយកន្តើយមិនបំពេញកាតព្វកិច្ចតាមកិច្ចសន្យានោះទេ លុះដល់ការកំណត់នៃការសងប្រាក់ដើម ចុងចម្លើយមិនព្រមសងប្រាក់ដើម និងការប្រាក់មកឱ្យដើមចោទតាមការកំណត់នោះទេ ទោះបីជាដើមចោទបានចុះទៅចចារ និងធ្វើការជូនដំណឹងដាស់តឿនឱ្យចុងចម្លើយទូទាត់ប្រាក់ក៏ដោយក៏ភាគីចុងចម្លើយនៅតែព្រងើយកន្តើយ និងគេចវេសមិនព្រមសងប្រាក់នៅជំពាក់ឡើយ ដែលនេះជាការបំពានកាតព្វកិច្ចនៃកិច្ចសន្យា និងមានចេតនាទុច្ចរិតក្នុងការមិនព្រមសងប្រាក់មកឱ្យដើមចោទ។

**៣.ចំណុចវិវាទ:** នៅក្នុងរឿងក្តីនេះពុំមានចំណុចវិវាទនោះទេ ។

**៤.ការអះអាងរបស់គូភាគី**

**៤.១ ការអះអាងរបស់ដើមចោទ**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្ញុំបាទសូមរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ទុកនៅដដែល ដោយហេតុថា កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] បានខ្ចីមកប្រាក់ពីកូនក្តីខ្ញុំបាទសម្រាប់យកទៅធ្វើការរកស៊ីចំនួន USD ៤៥,000 (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ដោយមានកិច្ចសន្យាធ្វើឡើងនៅចំពោះមុខមេធាវី និងមានលិខិតប្រគល់ទទួលប្រាក់ ហើយក៏បានដាក់ទ្រព្យដើម្បីធានាកាតព្វកិច្ចត្រឹមត្រូវតាមច្បាប់ ហើយមានមេធាវីប្រថាប់ត្រាបានឃើញ និងបញ្ជាក់ថាគូភាគីនៃកិច្ចសន្យាពិត ជាបានផ្តិតមេដៃនៅចំពោះមុខមេធាវីពិតប្រាកដមែន ដោយពុំមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។ នៅក្នុងការខ្ចីប្រាក់នេះចុងចម្លើយ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] បានព្រមព្រៀងជាមួយកូនក្តីខ្ញុំបាទឈ្មោះ [redacted] ផេង កំណត់យកការប្រាក់ចំនួន ៣% ក្នុងមួយខែ ដោយកំណត់រយៈពេលនៃការខ្ចីចំនួន ០៥ខែ គិតចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ដោយបង់ការប្រាក់ឱ្យបានទៀតទាត់ជារៀងរាល់ខែ ប៉ុន្តែរាល់ខែចុងចម្លើយមិនបានបំពេញកាតព្វកិច្ចដូចក្នុងកិច្ចសន្យានោះទេ ។ ចុងចម្លើយបានបង់ការប្រាក់យឺតយ៉ាវឱ្យកូនក្តីខ្ញុំបាទ និងមិនបានបង់ការប្រាក់នៅខែចុងក្រោយឱ្យទៅដើមចោទតាមការកំណត់នោះទេ ទោះបីជាកូនក្តីខ្ញុំបាទ ជូនដំណឹងអោយបង់ការប្រាក់ឱ្យបានទៀតទាត់យ៉ាងណាក៏ដោយ ក៏ចុងចម្លើយនៅតែព្រងើយកន្តើយមិនបំពេញកាតព្វកិច្ចតាមកិច្ចសន្យានោះទេ លុះដល់ការកំណត់នៃការសងប្រាក់ដើម ចុងចម្លើយនៅតែមិនព្រមសងប្រាក់ដើម និងការប្រាក់មកឱ្យកូនក្តីខ្ញុំបាទតាមការកំណត់នោះទេ ទោះបីជាកូនក្តីខ្ញុំបាទបានចុះទៅចរចារ និងធ្វើការជូនដំណឹងដាស់តឿនឱ្យចុងចម្លើយទូរទាត់ប្រាក់

តែភាគីចុងចម្លើយព្រងើយកន្តើយ និងគេចវេសមិនព្រមសងប្រាក់នៅជំពាក់ឡើយ ដែលនេះជាការបំពានកាតព្វកិច្ចនៃកិច្ចសន្យា និងមានចេតនាទុច្ចរិត ក្នុងការមិនព្រមសងប្រាក់។ ខ្ញុំបាទស្នើសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

ចំណុច "១" សុំឱ្យចុងចម្លើយឈ្មោះ [redacted] **នៅ** និងឈ្មោះ [redacted] សងប្រាក់ ដើមចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) មកឱ្យដើមចោទឈ្មោះ [redacted] **ផេង** ដោយហេតុថាៈ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] នៅ និងឈ្មោះ [redacted] បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] **ផេង** សម្រាប់ យកទៅធ្វើការរកស៊ីចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ដោយយកទ្រព្យធានាត្រឹមត្រូវតាមច្បាប់ និងមានមេធាវី ប្រថាប់ត្រាបានឃើញ និងបញ្ជាក់ថាគូភាគីនៃកិច្ចសន្យាពិតជាបានផ្ដិតមេដៃនៅចំពោះមុខ មេធាវីពិតប្រាកដមែន ដោយពុំមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

ចំណុច "២" សុំឱ្យចុងចម្លើយឈ្មោះ [redacted] **នៅ** និងឈ្មោះ [redacted] សងការប្រាក់ឱ្យដើមចោទចំនួន ៣% (បីភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃមិនអនុវត្តកាតព្វកិច្ច រហូតដល់ថ្ងៃសងគ្រប់ចំនួន ដោយហេតុថានៅពេលចុះកិច្ចសន្យា ភាគីចុងចម្លើយបានព្រមព្រៀង ក្នុងកិច្ចសន្យាខ្ចីទាត់លុយអំពីការបង់ការប្រាក់ ៣% ក្នុងមួយខែ។ ហេតុដូច្នេះទើបដើមចោទ ទាមទារការប្រាក់ដែលមិនទាន់ទូរទាត់សងចំនួន ៣% ក្នុងមួយខែ លើចំនួនទឹកប្រាក់ ៤៥,០០០$ (បួនម៉ឺនប្រាំពាន់ដុល្លាររអាមេរិក) គិតចាប់ពីពេល ដែលខកខានបង់រហូត ដល់ចុងចម្លើយសងប្រាក់អស់។

ចំណុច "៣" សុំទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងសេវាកម្មច្បាប់ចំនួន ២០,០០០ $ (ពីរម៉ឺនដុល្លារអាមេរិក) ពីចុងចម្លើយឈ្មោះ [redacted] **នៅ** និងឈ្មោះ [redacted] ដោយហេតុថា ការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយ និងការគេចវេសមិនសងប្រាក់បានបង្ក ឱ្យមានការខូចខាតពេលវេលា ក្នុងការទាមទារអោយសងប្រាក់ ពេលវេលានៃការដាស់តឿន និងការស្វែងរកការពិគ្រោះយោបល់ផ្នែកច្បាប់ ព្រមទាំងសេវាពឹងពាក់មេធាវី ហេតុនេះ ទើបដើមចោទទាមទារសំណងការខូចខាត ការខូចខាតពេលវេលា សំណងជំងឺចិត្ត និងសេវាកម្មច្បាប់ សរុបចំនួន ២០,០០០ (ពីរម៉ឺនដុល្លាររអាមេរិក) ពីចុងចម្លើយ។

ចំណុច "៤" សុំអនុវត្តសាលក្រមជាបណ្ដោះអាសន្នត្រង់ចំណុចទី១ ដោយហេតុថា ភាគីទាំងពីរ បានចុះកិច្ចសន្យាច្បាស់លាស់ដែលជាភស្តុតាងមិនអាចប្រកែកបាន និងបីទោះជាមានការប្តឹងទៅតុលាការជាន់ខ្ពស់ក៏នឹងមិនមានការប្រែប្រួលពីលទ្ធផល ហេតុនេះតុលាការគប្បី សម្រេចឱ្យអនុវត្តជាបណ្ដោះអាសន្នចំពោះសាលក្រមនេះ ដើម្បីជៀសវាងការបន្តខូចប្រយោជន៍របស់ដើមចោទកាន់តែធ្ងន់ធ្ងរ និងអូសបន្លាយពេលវេលា។

ចំណុច "៥" សុំឱ្យចុងចម្លើយឈ្មោះ [redacted] **នៅ** និងឈ្មោះ [redacted] បង់ពន្ធប្រាក់ប្រដាប់ក្តី និងពន្ធលើកម្មវត្ថុនៃបណ្ដឹង ដោយហេតុថា ចុងចម្លើយជាអ្នកបំពានកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ច និងគេចវេសពីការសងបំណុល រហូតធ្វើឱ្យដើមចោទប្តឹងទៅតុលាការ ដូចនេះចុងចម្លើយត្រូវជាអ្នកបង់ប្រាក់ប្រដាប់ក្តី ពន្ធដាក់ពាក្យសុំ និងពន្ធផ្សេងៗទៀតទាំងអស់។ ដូច្នេះដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់កូនក្តីខ្ញុំ ទើបខ្ញុំនៅតែប្តឹងសុំទាមទារប្រាក់ដូចមានក្នុងកម្មវត្ថុខាងលើ ។

**៤.២ ការអះអាងរបស់ចុងចម្លើយ**

-ចុងចម្លើយឈ្មោះ [redacted] បានធ្វើសេចក្ដីថ្លែងការណ៍ថា នាងខ្ញុំទទួលស្គាល់ត្រង់ចំណុចទី១ ថានាងខ្ញុំពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងចំណុចទី២ ការប្រាក់ចំនួន ៣% ក្នុងមួយខែ ពិតប្រាកដមែន ចំណែកចំណុចផ្សេងទៀត នាងខ្ញុំសុំបដិសេធចោលទាំងអស់ ព្រោះថានាងខ្ញុំពុំមានលទ្ធភាពសងទៅគាត់លើប្រាក់ដែលគាត់លើកឡើងក្រៅពីចំណុចទី១នោះទេ នាងខ្ញុំស្នើសុំសងប្រាក់ទៅដើមចោទវិញក្នុងមួយខែចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក រហូតគ្រប់ចំនួន ។

Scanned with CamScanner

## សំអាងហេតុ

-តាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថាៈ

១-តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ បញ្ជាក់បានថាភាគីចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] ពិតជាបានខ្ចីចងការប្រាក់ចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ពីដើមចោទឈ្មោះ [redacted] មែន ដោយមានមេធាវីប្រថាប់ត្រាពិតប្រាកដមែន ។

២-ចាប់ពីពេលដែលចុងចម្លើយបានខ្ចីប្រាក់ចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) រួចមកចុងចម្លើយមិនដែលបានសងប្រាក់ និងការប្រាក់ទៅឱ្យដើមចោទនោះទេ ពោលគឺរាប់ចាប់ពីពេលដែលខ្ចីប្រាក់រហូតមកដល់បច្ចុប្បន្ននេះគឺមិនដែលបានសងទាល់តែសោះ ។

៣.ភាគីដើមចោទបានប្តឹងទាមទារប្រាក់នៅជំពាក់សរុបចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ពីភាគីចុងចម្លើយឈ្មោះ [redacted] នៅ និងប្រពន្ធឈ្មោះ [redacted] ដោយអះអាងថា ភាគីចុងចម្លើយបានបំពានទៅលើលក្ខខណ្ឌ និងមិនបានបំពេញកាតព្វកិច្ចនៃការសងប្រាក់តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ រហូតមកដល់ពេលនេះគិតត្រឹមថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ភាគីចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ។ នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយបានទទួលស្គាល់ការទាមទារលើប្រាក់ដើមនេះដែរ។ ហេតុនេះតុលាការទទួលស្គាល់អង្គហេតុបង្កើតកិច្ចសន្យាខ្ចីបរិភោគ ឃើញថាចុងចម្លើយពិតជាបានបំពានកាតព្វកិច្ចបង់ប្រាក់ទៅដើមចោទ ផ្អែកតាមមាត្រា ៥៧៨ និងមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី ពិតប្រាកដមែន ។

៤.ភាគីដើមចោទបានទាមទារឱ្យចុងចម្លើយសងការប្រាក់ចំនួន ៣% (បីភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃមិនអនុវត្តកាតព្វកិច្ច រហូតដល់ថ្ងៃសងគ្រប់ចំនួន ។ យោងតាមមាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រង់ប្រការ ១ បានបញ្ជាក់ថា អត្រាការប្រាក់ត្រូវបានកំណត់មិនឱ្យលើសពី ១៨% ក្នុងមួយឆ្នាំ ។ ម្យ៉ាងវិញទៀតគូភាគីបានព្រមព្រៀងគ្នាកំណត់អត្រាការប្រាក់ចំនួន ៣% ក្នុងមួយខែនៅពេលដែលធ្វើកិច្ចសន្យាខ្ចីប្រាក់ ។ ហេតុនេះគប្បីតុលាការសម្រេចបង្គាប់ឱ្យចុងចម្លើយបង់អត្រាការប្រាក់ចំនួន ១៨% លើប្រាក់ដើមចាប់ពីពេលខកខានសងរហូតដល់ថ្ងៃសងគ្រប់ចំនួន ។

៥.ដើមចោទបានប្តឹងទាមទារឱ្យចុងចម្លើយទទួលខុសត្រូវ លើសេវាពិគ្រោះយោបល់តាមផ្លូវច្បាប់ចំនួន USD ២០,០០០ (ពីរម៉ឺនដុល្លារអាមេរិក) ការទាមទារនេះពុំមានភស្តុតាងបញ្ជាក់អំពីទំហំនៃការខូចខាតច្បាស់លាស់ដូចការទាមទារឡើយ ប៉ុន្តែតុលាការយល់ឃើញថា ពិតជាមានការខូចខាតដែលបង្កឡើងដោយភាគីសហចុងចម្លើយពិតប្រាកដមែន ហេតុនេះគប្បីតុលាការលើកយកមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី មកធ្វើការពិចារណាតាមការជាក់ស្តែង ។

៦.នាពេលទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយទទួលស្គាល់ជំពាក់ប្រាក់ដើមទាំងអស់ និងសុំឱ្យតុលាការសម្រេចតាមច្បាប់ ដូច្នេះយោងតាមមាត្រា១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការពុំចាំបាច់ពិនិត្យភស្តុតាងទេ។

៧.ដើមចោទបានសុំឱ្យតុលាការចេញសាលក្រមប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ចំណុចនេះដោយហេតុថាតាមកិច្ចសន្យាខ្ចីប្រាក់ និងតាមការអះអាងរបស់ដើមចោទឃើញថា ក្រោយពីបានខ្ចីប្រាក់ពីដើមចោទរួចមកចុងចម្លើយពុំបានទូទាត់បំណុលមកឱ្យដើមចោទនោះទេ ដោយចុងចម្លើយនៅជំពាក់ប្រាក់សរុបចំនួន USD ៤៥,០០០

Scanned with CamScanner

(បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ប្រាកដមែន ប្រសិនបើមិនអនុញ្ញាតឱ្យមានការអនុវត្តបណ្តោះអាសន្នទេនោះ អាចធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ដើមចោទកាន់តែធ្ងន់ធ្ងរ ទម្រាំសាលក្រមចូលជាស្ថាពរ ហេតុនេះគប្បីតុលាការពិចារណាទទួលយកការស្នើសុំនេះដោយផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៨. ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

**១.** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] នៅ ភេទប្រុស កើតឆ្នាំ១៩៧០ និងប្រពន្ធឈ្មោះ [redacted] កើតឆ្នាំ ១៩៧២ សងប្រាក់ដើមចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ទៅឱ្យដើមចោទឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ ១៩៦៩ ។

**២.** បង្គាប់ឱ្យចុងចម្លើយ សងការប្រាក់ក្នុងអត្រាចំនួន ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំលើប្រាក់ដើមចំនួន USD ៤៥,០០០ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួនទៅឱ្យដើមចោទ ។

**៣.** បង្គាប់ឱ្យចុងចម្លើយសងប្រាក់សម្រាប់ការខាតបង់ពេលវេលា និងចំណាយផ្សេងៗចំនួន ៨,០០០,០០០ (ប្រាំបីលាន) រៀល ទៅឱ្យដើមចោទ ។ ការស្នើសុំលើសពីនេះសម្រេចច្រានចោល ។

**៤.** សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី ១ នៃសេចក្តីសម្រេចបញ្ចប់ ។

**៥.** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ។

**សាលក្រមនេះ គូភាគីអាចប្តឹងឧទ្ធរណ៍តាមមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។**

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

តាកែវ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

តាកែវ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២២

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner